*សិក្ខាសាលាស្តីពី*
*ភាពចាំបាច់នៃការអប់រំផ្នែកសីលធម៌នៅក្នុងការអភិវឌ្ឍសង្គមកម្ពុជានាពេលបច្ចុប្បន្ន*
*សាកលវិទ្យាល័យមេគង្គកម្ពុជា*
*០៤មករា ២០១០*

# តើសីលធម៌ជាអ្វី?

**លោក យន់ សំនៀង**

ទីប្រឹក្សា, មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជា

Email: yunsamneang@gmail.com

សង្គមមនុស្សមានការប្រែប្រួលតាមទំនោរ តាមស្ថានភាពសង្គមផ្លាស់ប្តូរនៃសង្គម តាមសំពាធពីខាងក្រៅផ្សេងៗ ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច និងការទទួលស្គាល់នូវតំលៃនៃវប្បធម៌ផ្សេងៗ។ ការផ្លាស់ប្តូរនឹងនាំមកនូវភាពរីកចំរើនដល់សង្គមមនុស្សដោយមានការចាប់អារម្មណ៍និងការយកចិត្តទុកដាក់ដល់សារៈប្រយោជន៍នៃការផ្លាស់ប្តូរតាមលក្ខណៈតក្កនិយម និងវិទ្យាសាស្ត្រនិយម ព្រមទាំងមានលក្ខណៈសីលធម៌និងមនុស្សធម៌។ ក្នុងន័យម្យ៉ាងទៀត ការផ្លាស់ប្តូរអាចនាំមកនូវភ័យន្តរាយនិងមហន្តរាយតាមស្ថានភាពរឹងត្អឹងនិងលក្ខណៈចង្អៀតចង្អល់ក្នុងការចាប់អារម្មណ៍ ពិចារណានិងការទទួលយកនូវទស្សនៈខុសប្លែកតែសមស្របទៅតាមកាលៈទេសៈនៃការផ្លាស់ប្តូរ។

សង្គមខ្មែរមានការផ្លាស់ប្តូរគួរអោយចាប់អារម្មណ៍បំផុតក្នុងរយៈពេលប្រហែលហាសិបឆ្នាំកន្លងមកនេះ។ ព្រឹត្តិការណ៍មួយចំនួនមុនសម័យកាលប្រកាសឯករាជ្យឆ្នាំ១៩៥៣ ការវិវត្តក្រោយសម័យឯករាជ្យរហូតដល់ពេលរង្គោះរង្គើនៃស្ថានភាពនយោបាយមុនឆ្នាំ១៩៧០ និងការប្រកាសជាសាធារណៈរដ្ឋ ព្រមទាំងសង្គ្រាមស៊ីវិលរហូតដល់ឆ្នាំ១៩៧៥ដែលនាំមកនូវវិនាសកម្មដ៏ជូរចត់នៃជនជាតិខ្មែរទាំងនៅទីក្រុងនិងជនបទហើយប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយដែលបានចុះថយផ្នែកសេដ្ឋកិច្ច ថ្វីបើជាមានជំនួយសេដ្ឋកិច្ចពីប្រទេសនានាតាមប្លុកសេរី ក៏ដូចជាប្លុកកុម្មុយនីស្ត។

វិបត្តិពីការផ្លាស់ប្តូរដែលខ្មែរភាគច្រើនបានចាប់អារម្មណ៍បំផុតគឺវិនាសកម្មនៃការសំលាប់រង្គាលនៅក្នុងរបបខ្មែរក្រហម ឬវាលពិឃាតដែលខ្មែរបានឆ្លងកាត់ដ៏ជូរចត់ក្នុងសម័យកាលឆ្នាំ១៩៧៥ ដល់ ១៩៧៩។

ការរៀបរាប់ខ្លីៗខាងលើនេះ ខ្ញុំមិនមានបំណងនឹងបកស្រាយនូវបន្លាស់ប្តូរនៃរបបរស់នៅផ្សេងៗនៃប្រទេសកម្ពុជាក្នុងលក្ខណៈនយោបាយនោះទេ តែគ្រាន់តែជាការលើកបញ្ចាក់ខ្លីៗនូវការផ្លាស់ប្តូរដែលជនជាតិខ្មែរឆ្លងកាត់និងគួរតែត្រូវចាប់អារម្មណ៍ ព្រមទាំងធ្វើការពិចារណាដើម្បីធ្វើការស្វែងរកនូវទស្សនៈនិង

ការយល់ដឹងផ្សេងៗក្នុងការរួមចំណែកផ្លាស់ប្តូរសង្គមអោយមានលក្ខណៈវិជ្ជមាន មានស្ថេរភាព និងវឌ្ឍនៈភាពដោយកាត់បន្ថយនូវការខូចខាតជាយថាហេតុ។

**តើសីលធម៌ជាអ្វី?**

ជាទូទៅសីលធម៌ត្រូវបានគេអោយនិយមន័យប្លែកៗគ្នាមួយចំនួន។ តាមរយៈការប្រើប្រាស់ជាញឹកញាប់ ការអោយនិយមន័យសីលធម៌គឺសំដៅទៅលើនិយាម ឬគោលការណ៍មួយចំនួនដែលមនុស្សប្រតិបត្តិ។ ក្នុងករណីដែលនិយាយពី “សីលធម៌នៃការព្យាបាល” ឬសីលធម៌វិជ្ជសាស្រ្ត គឺសំដៅទៅលើនិយាមជាក្រឹត្យដែលជាការណែនាំនូវការប្រព្រឹត្ត ឬអនុវត្តន៍របស់គ្រូពេទ្យដែលចូលរួមក្នុងការសហការ និងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកជំងឺ។ ក្នុងលំនាំដូចគ្នាផងដែរ ការនិយាយពីសីលធម៌របស់គ្រីស្តសាសនា យើងសំដៅទៅលើគោលការណ៍ដែលដាក់ចុះ និងណែនាំនូវឥរិយាបទសំរាប់គ្រីស្តបរិសទ ដែលជាក្រឹត្យនៃការប្រតិបត្តិដោយស្តែងចេញតាមរយៈគោលការណ៍ទាំងដប់ប្រការ (Ten Commandments)។

ទស្សនវិទូមួយចំនួនមិនបានប្រើពាក្យនេះតាមន័យរបស់ពាក្យនោះទេ នៅពេលដែលគេនិយាយអំពីសីលធម៌។ កម្មបទដែលបានធ្វើការសិក្សាក្នុងសីលធម៌ត្រូវបានគេហៅថា “ទ្រឹស្តីសីលធម៌” (Ethical theories) ដែលទាក់ទងនឹងសំណួរមួយចំនួនដូចជា៖ តើមនុស្សគួរតែត្រូវប្រកាន់អាកប្បកិរិយាបែបណា (How men ought to behave?)? ឬ តើអ្វីជាជីវិតប្រកបដោយកុសលរបស់មនុស្ស (What is the good life for men?)? ។ល។

**ប្រភពនៃសីលធម៌ (Origin of Ethics)**

ស្ថាប័នជាប្រភពនៃសីលធម៌ដែលយើងគួរផ្តោតអារម្មណ៍គឺ៖

**១. ស្ថាប័នសិទ្ធិមនុស្ស**

យោងតាមសេចក្តីប្រកាសផ្នែកសិទ្ធិមនុស្សនៅក្នុងឆ្នាំ២០០០ នៅរដ្ឋកាលីហ្វ័ញ៉ា សហរដ្ឋអាមេរិកបានថែងពីភាពស្មើគ្នានៃសិទ្ធិរបស់មនុស្សដោយមិនប្រកាន់នូវពូជសាសន៍ សញ្ជាតិ ភេទ  ជំនឿសាសនា (សិទ្ធិប្រកាន់យកនូវជំនឿសាសនាផ្សេងៗ តាមការយល់ដឹង និងអនុវត្តន៍វិសម្បទាផ្សេងៗ។

ក្រោមការយល់ដឹងនៃការមិនប្រកាន់នៃមនុស្សជាតិ (Non Discrimination Acts) មនុស្សផងទាំងឡាយគួរអនុញ្ញាតិនិងបំប៉នអប់រំអោយដូចជាតំរូវការចាំបាច់នៃជីវិត ដូចជាម្ហូបអាហារ សំលៀកបំពាក់សមរម្យ ជំរកជ្រកនៅគួរសម និងការយកចិត្តទុកដាក់ក្នុងការឧបត្ថម្ភខាងផ្នែកព្យាបាលនិងសុខាភិបាល។

អង្គការសិទ្ធិមនុស្សជាតិនិងអន្តរជាតិ ADHOCS បានរួមសហការយ៉ាងជិតស្និទ្ធិក្នុងគោលបំណងតែមួយក្នុងការពង្រីកនូវការយល់ដឹងពីសិទ្ធិមនុស្ស ដោយការគោរពសិទ្ធិរវាងគ្នានិងគ្នាដោយបណ្តុះបណ្តាលនូវថ្នាលសីលធម៌ដែលជាឫសគលពិតៗនៃការកាត់បន្ថយនូវអំពើរំលោភ និងហឹង្សាដើម្បីសំរេចបាននូវសន្តិភាពនិងសុខមាលភាពនៃប្រជាជាតិខ្មែរ។

## ២. ស្ថាប័នសាសនា

ប្រទេសកម្ពុជាបានប្រកាន់យកព្រះពុទ្ធសាសនាជាសាសនារបស់ជាតិ។ សាសនាដទៃទៀតដូចជាអ៊ីស្លាមសាសនាបានរីកដុះដាលនិងអនុវត្តតាមជំនឿរបស់ខ្មែរអ៊ីស្លាម ឬចាម ស្ទើគ្រប់ខេត្តក្រុង។ ចាប់តាំងពីឆ្នាំ១៩៩០មក សាសនាគ្រីស្តក៏មានការរីកដុះដាលផងដែរ។ ការអប់រំ និងការសហនៃការអប់រំរបស់សាសនានានាគឺក្នុងគោលបំណងដូចគ្នាគឺ ដើម្បីសន្តិភាពនិងសុខមាលភាពតាមមធ្យោបាយអប់រំផ្សេងៗនៃសីលធម៌ បានសរបញ្ជាក់ពីភាពចុះសំរុងនៃទស្សនៈ និងជំនឿផ្សេងៗគ្នាក្នុងការថែរក្សានូវទំនៀមទំលាប់ ប្រពៃណីនៅក្នុងប្រទេសកម្ពុជា។ ការបញ្ជ្រាបសីលធម៌ក្នុងការទូន្មានផ្នែកសាសនាត្រូវបានធ្វើឡើងតាមគ្រួសារ សហគមរបស់សាសនិកនីមួយៗ។

## ៣. ស្ថាប័នសង្គម

គោលបំណងនៃការចងក្រងនីតិច្បាប់សង្គម

- ការពារនូវការរំលោភ
- អនុវត្តន៍នូវប្រការច្បាប់
- លើកកំពស់ការចាប់អារម្មណ៍និងការយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ច
- ចំណាប់អារម្មណ៍នៃសិទ្ធិ
    - សិទ្ធិក្នុងការដឹងឮ និងយល់ដឹង
    - សិទ្ធិឯកជន
    - សិទ្ធិនៃទ្រព្យសម្បត្តិ
- ចំណាប់អារម្មណ៍នៃកាតព្វកិច្ចផ្ទាល់ខ្លួន
    - បណ្តុះបណ្តាលនូវជំនឿទុកចិត្ត
    - ការប្រព្រឹត្តិដោយតម្លាភាព

**ទំនាក់ទំនងរវាងស្ថាប័នទាំង៣**



- កាត់បន្ថយនូវការរំលោភរវាងមនុស្សនិងមនុស្សដូចគ្នា
    - រដ្ឋអំណាច៖ លប់បំបាត់នូវការបំពានដោយប្រើប្រាស់អំនាចរដ្ឋជាអំនាចផ្ទាល់ខ្លួនរំលោភវាស្រ្តស្លូតត្រង់
    - ការរំលោភបំពានដោយសំអាងលើសំភារៈនិយម៖ ការប្រើប្រាស់ទ្រព្យសម្បត្តិបំពារបំពានទៅលើជនក្រីក្រនិងស្លូតត្រង់
    - ការរំលោភដោយរូបកាយ៖បំពានដោយប្រើប្រាស់អំពើហឹង្សាក្នុងគ្រួសារ
- លើកកំពស់ការយល់ដឹងពីសីលធម៌
- បង្កើននូវការអប់រំសីលធម៌សាសនាផងដែរ
- ចាប់អារម្មណ៍នឹងស្ថានភាពសង្គមបច្ចុប្បន្ន និងស្វែងរកវិធីសាស្រ្តថ្មីៗក្នុងការអប់រំ
- ពង្រឹងការអនុវត្តច្បាប់សង្គម
    - បង្កើនការចាប់អារម្មណ៍ពីតួនាទីច្បាប់ និងការអនុវត្តច្បាប់
    - ពិន័យនិងផ្តន្ទាទោសដោយមិនរើសអើង/លំអៀង

## ភាពចាំបាច់នៃនៃសីលធម៌

- ភាពចាំបាច់នៃសីលធម៌សំរាប់បុគ្គលខ្លួនឯង
- ភាពចាំបាច់នៃសីលធម៌សំរាប់គ្រួសារ
- ភាពចាំបាច់នៃសីលធម៌សំរាប់សង្គម
- ភាពចាំបាច់នៃសីលធម៌សំរាប់ពិភពលោក